# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១
# ផ្នែកទី៣៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី



# ការចិញ្ចឹមបសុសត្វ និងបសុបក្សី

ការចិញ្ចឹមបសុសត្វ និងបសុបក្សី នៅកម្ពុជា ជាសកម្មភាពកសិកម្មដ៏សំខាន់មួយ ដែលធ្វើឡើងដោយគ្រួសារកសិកម្ម ព្រមទាំងដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និងផ្តល់ប្រាក់ចំណូលដល់គ្រួសារនៅទីជនបទ។ ក្នុងចំណោមគ្រួសារកសិកម្មសរុបនៅប្រទេសកម្ពុជាមានគ្រួសារចូលរួមសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី និងសត្វល្អិត ចំនួន ១.៦១០.០០០ គ្រួសារ។ ការអង្កេតកសិកម្មកម្ពុជា បានបែងចែកបសុសត្វជាពីរគឺ ប្រភេទបសុសត្វធំ មានដូចជា គោ ក្របី សេះ និងប្រភេទបសុសត្វតូច មានដូចជា ជ្រូក និងពពែ។

តារាងទី ៣.១ ចំនួនគ្រួសារចិញ្ចឹម បសុសត្វ បសុបក្សី (គិតជាពាន់)

| ប្រទេសកម្ពុជា (ចំនួនគ្រួសារ គិតជាពាន់) | | | |
|---|---|---|---|
| គ្រួសារសរុបមាន ផលិតកម្ម បសុសត្វ បសុបក្សី និងសត្វល្អិត | បសុសត្វធំ (គោ ក្របី សេះ) | បសុសត្វតូច (ជ្រូក ពពែ) | បសុបក្សី (មាន់ ទា ត្រចៀកកាំ) |
| ១.៦១០ | ៨៣២ | ១១៨ | ១.២៦០ |

ចំនួនគ្រួសារកសិកម្មដែលបានចូលរួមចិញ្ចឹមបសុសត្វធំ និងបសុបក្សី បានបង្ហាញថា នៅតំបន់វាលទំនាបមានចំនួនច្រើនជាងគេ ដោយសារតំបន់នេះមានអំណោយផលល្អសម្រាប់សកម្មភាពចិញ្ចឹមសត្វ ហើយមានចំនួនច្រើនបន្តបន្ទាប់ដោយតំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងមានចំនួនគ្រួសារតិចជាងគេនៅតំបន់ ភ្នំ និងខ្ពង់រាប។ ទោះជាយ៉ាងនេះក្តីចំនួនគ្រួសារកសិកម្មដែលចូលរួមចិញ្ចឹមបសុសត្វប្រភេទតូចមានចំនួនច្រើនជាងគេនៅតំបន់បឹងទន្លេសាប និងតំបន់វាលទំនាប ហើយមានចំនួនតិចជាងគេ គឺនៅតំបន់ឆ្នេរសមុទ្រ។

រូបទី ៣.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹម បសុសត្វ បសុបក្សី តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

## បសុសត្វធំ






*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

# បសុសត្វធំ

## សត្វគោ

ជាទូទៅបសុសត្វប្រភេទធំ ដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេ គឺសត្វគោ មានប្រមាណ ៣.៣៨៤.០០០ក្បាល បានរាយការណ៍នៅទូទាំងប្រទេសកម្ពុជា។ នៅតំបន់វាលទំនាបមានចិញ្ចឹមគោច្រើនជាងគេមានចំនួន ១.៤៥៨.០០០ក្បាល ហើយមានចំនួនច្រើនបន្តបន្ទាប់ដោយតំបន់បឹងទន្លេសាបចំនួន ១.១៨៥.០០០ក្បាល និងតំបន់ភ្នំ និងខ្ពង់រាបចំនួន ៥៧៤.០០០ក្បាល ហើយតំបន់ឆ្នេរសមុទ្រមានគ្រួសារកសិកម្មចិញ្ចឹមគោតិចជាងគេចំនួន ១៦៧.០០០ក្បាល។

**រូបទី ៣.២. ចំនួនគ្រួសារកសិកម្មបានរាយការណ៍ពីការចិញ្ចឹមគោ តាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

នៅទូទាំងប្រទេសកម្ពុជា ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមគោជាហ្វូងគិតជាមធ្យមមានប្រមាណ ៤,៤ ក្បាលក្នុង១គ្រួសារ ។ ចំនួនគ្រួសារកសិកម្មភាគច្រើនចិញ្ចឹមគោជាហ្វូងពី ៣ ទៅ ៩ ក្បាល មានចំនួន ៤៣៤.០០០គ្រួសារ ហើយបន្ទាប់មកការចិញ្ចឹមគោជាហ្វូងចំនួនពី១ ទៅ ២ក្បាល មានចំនួន ២៨៧.០០០ គ្រួសារ និងមានតែ ៥៧.០០០គ្រួសារ ប៉ុណ្ណោះ បានរាយការណ៍ថាមានចិញ្ចឹមគោជាហ្វូងច្រើនជាងចំនួន ១០ក្បាល។

**រូបទី ៣.៣. ចំនួនគ្រួសារកសិកម្មបានចិញ្ចឹមគោចែកតាមហ្វូង ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ចំនួនហ្វូងគោដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើន គឺជាគោញីមានចំនួន១,៧៥០ពាន់ក្បាល ហើយមានប្រមាណ ៥២% មានអាយុលើសពី២ឆ្នាំ ចំណែកគ្រួសារកសិកម្មចិញ្ចឹមគោឈ្មោលមានអាយុ ២ឆ្នាំ ឬច្រើនជាង មានចំនួនតិចតួចប៉ុណ្ណោះមានក្នុងគ្រួសារ។

**រូបទី ៣.៤. ចំនួនគោ ចែកតាម អាយុ ភេទ ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ចំនួនសត្វគោភាគច្រើន ដែលមានចិញ្ចឹមក្នុងគ្រួសារកសិកម្មគឺបានមកពីកាកើតកូនបន្តពូជ ច្រើនជាងលើសលុបពីការទិញគោចូលយកមកចិញ្ចឹម នៅតំបន់វាលទំនាប តំបន់បឹងទន្លេសាប និងតំបន់ភ្នំ និងខ្ពង់រាប ដោយឡែកតែនៅតំបន់ឆ្នេរសមុទ្រ មានលក្ខណៈខុសពីតំបន់ផ្សេងៗទៀត គឺមានចំនួនសត្វគោទិញចូលយកមកចិញ្ចឹម ច្រើនជាងចំនួនសត្វគោកើតកូនបន្តពូជយកមកចិញ្ចឹម គឺទិញចូលមានចំនួន ៣០.០០០ ក្បាល និងគោដែលកើតមានចំនួន ២៩.០០០ក្បាល។

**រូបទី ៣.៥. ចំនួនគោ បានកើត និងទិញ គិតតាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ចំពោះបម្រែបម្រួលសត្វគោក្នុង១២ ខែកន្លងមកដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មបានបង្ហាញថា ភាគច្រើន គឺចិញ្ចឹមលក់រស់មានចំនួន ៥០៥.០០០ក្បាល ហើយសត្វគោដែលបានងាប់មានចំនួន ១១០.០០០ ក្បាល ខណៈដែលសត្វគោ បានបាត់បង់ដោយការលួចមានចំនួន ៧.០០០ក្បាល នៅទូទាំងប្រទេសក្នុងរយៈពេល១២ ខែកន្លងមក។

**រូបទី ៣.៦. ចំនួនបម្រែបម្រួលសត្វគោ ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ការចិញ្ចឹមគោរបស់គ្រួសារកសិកម្មនៅកម្ពុជា មានភាគរយតិចជាង ១% ចំនួនប្រមាណ ៦.០០០ គ្រួសារប៉ុណ្ណោះ ដែលបានរាយការណ៍ថាការចិញ្ចឹមគោរបស់ពួកគាត់មានកិច្ចសន្យាផលិតកម្ម ឬកិច្ចសន្យាទីផ្សារ។ សម្រាប់លក្ខណៈចិញ្ចឹមសត្វគោរបស់គ្រួសារកសិកម្មវិញបានបង្ហាញថាចិញ្ចឹមគោតាមធម្មជាតិឱ្យស៊ីស្មៅមានចំនួន ៧១៥.០០០គ្រួសារ ខណៈដែលការចិញ្ចឹមគោឱ្យស៊ីចំណី និងលាយគ្នាតាមធម្មជាតិ មានចំនួន ៦២.០០០០ គ្រួសារ។



## សត្វក្របី

គ្រួសារកាន់កាប់កសិកម្មនៅទូទាំងប្រទេសកម្ពុជា បានរាយការណ៍ថាមានចំនួនសត្វក្របីសរុបប្រមាណ ៣៥៦.០០០ក្បាល នៅតំបន់វាលទំនាបមានសត្វក្របីច្រើនជាងគេ ១៥៩.០០០ក្បាល បន្ទាប់មកតំបន់បឹងទន្លេសាបមានចំនួន ១២៩.០០០ក្បាល ហើយនៅតំបន់ភ្នំ និងខ្ពង់រាប មានចំនួន ៥៤.០០០ ក្បាល និងតំបន់ឆ្នេរសមុទ្រមានចំនួនតិចជាងគេប្រមាណ ១៤.០០០ក្បាល។

**រូបទី ៣.៧. ចំនួនគ្រួសារកសិកម្មបានចិញ្ចឹមសត្វក្របីចែកតាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

នៅទូទាំងប្រទេសកម្ពុជា ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមសត្វក្របីជាហ្វូងគិតជាមធ្យម មានប្រមាណ ៥,១ក្បាលក្នុង១គ្រួសារ។ ចំនួនគ្រួសារកសិកម្មភាគច្រើនចិញ្ចឹមសត្វក្របីជាហ្វូងពី ៣ ទៅ ៩ ក្បាល មានចំនួន ៤២.០០០គ្រួសារ ហើយបន្ទាប់មកការចិញ្ចឹមសត្វក្របីជាហ្វូងចំនួនពី១ ទៅ ២ក្បាល មានចំនួន ២០.០០០គ្រួសារ និងមានតែ ៦.០០០គ្រួសារប៉ុណ្ណោះ បានរាយការណ៍ថាមានចិញ្ចឹមសត្វក្របីជាហ្វូងច្រើនជាងចំនួន ១០ក្បាល។

**រូបទី ៣.៨. ចំនួនគ្រួសារកសិកម្មបានចិញ្ចឹម ចែកតាមហ្វូងសត្វក្របី ប្រទេសកម្ពុជាឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ចំនួនហ្វូងសត្វក្របីដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើន គឺជាក្របីញី ហើយមានប្រមាណ៥១% មានអាយុលើសពី២ឆ្នាំ ចំណែកគ្រួសារកសិកម្មចិញ្ចឹមក្របីឈ្មោលមានអាយុ ២ឆ្នាំ ឬច្រើនជាង មានចំនួនតិចតួចប៉ុណ្ណោះមានក្នុងគ្រួសារ។

**រូបទី ៣.៩. ចំនួនសត្វក្របីចែកតាម អាយុ ភេទ ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

## បសុសត្វតូច

### សត្វជ្រូក

ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមសត្វជ្រូក នៅទូទាំងប្រទេសមានប្រមាណ ១១៦.០០០ គ្រួសារ នៅតំបន់ទន្លេសាបមានចំនួនច្រើនជាងគេប្រមាណ ៤៩.០០០គ្រួសារ បន្ទាប់មកនៅតំបន់វាលទំនាបមានចំនួន ៣៤.០០០គ្រួសារ និងនៅតំបន់ឆ្នេរសមុទ្រមានចំនួនតិចជាងគេ ៧.០០០គ្រួសារ។

**រូបទី ៣.១០. ចំនួនគ្រួសារចិញ្ចឹមជ្រូក និងចំនួនជ្រូកដែលមាន ចែកតាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

នៅទូទាំងប្រទេសកម្ពុជា ចំនួនសត្វជ្រូកដែលបានចិញ្ចឹមគិតជាមធ្យមក្នុងមួយគ្រួសារគឺ ៨,៧ ក្បាល។ គ្រួសារកសិកម្មចិញ្ចឹមជ្រូកចំនួន ពី ១ ទៅ ២ក្បាល មានចំនួន ៣៨.០០០គ្រួសារ ហើយចិញ្ចឹមជ្រូកចំនួនពី ៣ ទៅ ៩ក្បាល មានចំនួន ៤៣.០០០គ្រួសារ ចំណែកការចិញ្ចឹមជ្រូកចំនួនពី១០ ទៅ ១៩ក្បាល មានចំនួន ២១.០០០គ្រួសារ និងការចិញ្ចឹមជ្រូកចំនួនលើសពី ២០ក្បាល មានចំនួន ១៥.០០០គ្រួសារ។

**រូបទី ៣.១១. ចំនួនគ្រួសារកសិកម្មចិញ្ចឹមជ្រូកតាមចំនួនជ្រូក ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ការចិញ្ចឹមជ្រូករបស់គ្រួសារកសិកម្មភាគច្រើនអាយុជ្រូកតិចជាង១ឆ្នាំ មានចំនួន ៨០១.០០០ក្បាល ប្រមាណជា ៧៩% ហើយជ្រូកញីមានចំនួន ៥៨២.០០០ក្បាល ប្រមាណជា ៥៨ % ដែលបានចិញ្ចឹមនៅទូទាំងប្រទេសកម្ពុជា។

**រូបទី ៣.១២. ចំនួនភាគរយសត្វជ្រូក ចែកតាមអាយុ និងភេទ ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ចំនួនសត្វជ្រូកភាគច្រើនដែលមានចិញ្ចឹមក្នុងគ្រួសារកសិកម្ម គឺបានមកពីកាកើតកូនបន្តពូជ ច្រើនជាងលើសលុបពីការទិញជ្រូកចូលយកមកចិញ្ចឹម។

**រូបទី ៣.១៣. ចំនួនជ្រូក បានកើត និងទិញចែកតាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

## បសុបក្សី






*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ការប្រមូលទិន្នន័យអង្កេតកសិកម្ម ត្រូវបានប្រមូលព័ត៌មានពីការចិញ្ចឹមបសុបក្សីផងដែរ។ នៅក្នុងតារាងទិន្នន័យលទ្ធផលដែលបានផ្សព្វផ្សាយអំពីបសុបក្សី មានដូចជា មាន់ ទា និង ក្ងានហើយរបាយការណ៍នេះផ្ដោតតែលើការចិញ្ចឹមបសុបក្សីដែលសំខាន់ជាងគេគឺសត្វមាន់។



## សត្វមាន់

មាន់ គឺជាប្រភេទបសុបក្សីដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេមានចំនួន ១.២១៦.០០០ គ្រួសារ ស្មើនឹង ៤៥លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់វាលទំនាប មានគ្រួសារចិញ្ចឹមមាន់ច្រើនជាងគេចំនួន ៤៦៨.០០០គ្រួសារ បន្ទាប់មកតំបន់បឹងទន្លេសាបមាន ៤៤១.០០០គ្រួសារ ហើយតំបន់ឆ្នេរសមុទ្រមានចំនួន ១២២.០០០គ្រួសារ និងតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១០៧.០០០គ្រួសារ។ ចំនួនមាន់ជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ៣៧,៧ក្បាល។

**រូបទី ៣.១៤. ចំនួនគ្រួសារកសិកម្មចិញ្ចឹមមាន់ ចែកតាមតំបន់ ឆ្នាំ២០២១**



*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

នៅតំបន់វាលទំនាបបានបង្ហាញថាមានចំនួនមាន់ច្រើនជាងគេសរុបប្រមាណ ១៧លានក្បាល។ នៅតំបន់បឹងទន្លេសាបមានចំនួន ១៥,២លានក្បាល និងនៅតំបន់ឆ្នេរសមុទ្រមានចំនួន ៤,៦លានក្បាល ហើយចំនួនមាន់នៅតំបន់ភ្នំ និងខ្ពង់រាប មិនបានបង្ហាញ។

**រូបទី ៣.១៥. ចំនួនមាន់សរុប ចែកតាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

បម្រែបម្រួលសត្វមាន់ក្នុងរយៈពេល១២ ខែកន្លងមក ការចិញ្ចឹមមាន់របស់គ្រួសារកសិកម្មគឺបានមកពីការកើតកូនបន្តពូជ ច្រើនជាងលើសលុបពីការទិញមាន់ចូលយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប មានមាន់កើតកូនបន្តពូជច្រើនជាងគេចំនួន ១៤,៨លានក្បាល បន្ទាប់មកនៅតំបន់វាលទំនាប មាន ១១,៣លានក្បាល ហើយតំបន់ឆ្នេរសមុទ្រមានប្រមាណ ៥ លានក្បាល និងនៅ តំបន់ភ្នំ និងខ្ពង់រាប មាន ៤,៨លានក្បាលតិចជាងគេ។ ចំណែកឯចំនួនមាន់ដែលបានទិញចូលយកមកចិញ្ចឹមវិញ គឺមាននៅតំបន់បឹងទន្លេសាប និង តំបន់វាលទំនាប មានប្រមាណជាង ១ លានក្បាល ហើយនៅ តំបន់ឆ្នេរសមុទ្រ និង តំបន់ភ្នំ និងខ្ពង់រាប មិនមានទិន្នន័យបង្ហាញ។

**រូបទី ៣.១៦. ចំនួនមាន់បានកើត និងទិញ ចែកតាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

មូលហេតុចម្បងនៃការចិញ្ចឹមមាន់ របស់គ្រួសារកសិកម្មបានបង្ហាញថា លក់រស់មានចំនួនប្រមាណ ១៥,៦លានក្បាល ហើយចំនួន ១១,២លានក្បាល ត្រូវបានកាប់យកសាច់ និងមាន ១៩,៤លានក្បាល បានងាប់ដោយសារធម្មជាតិជំងឺ និងជំងឺឆ្លងផ្សេងៗ ក្នុងរយៈពេលយោង ឆ្នាំ២០២១។

**រូបទី ៣.១៧. ចំនួនបម្រែបម្រួលមាន់រយៈពេល១២ ខែកន្លងមក ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*



## សត្វទា

ទា គឺជាប្រភេទបសុបក្សីទី២ ដែលគ្រួសារកសិកម្មភាគច្រើនបានចិញ្ចឹមមានចំនួន ២៣៧.០០០ គ្រួសារ ស្មើនឹង ១៤,៧លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់វាលទំនាប មានគ្រួសារចិញ្ចឹមទាច្រើនជាងគេចំនួន ៩៤.០០០គ្រួសារ បន្ទាប់មកតំបន់បឹងទន្លេសាបមាន ៨១.០០០គ្រួសារ ហើយតំបន់ឆ្នេរសមុទ្រមានចំនួន ៣២.០០០គ្រួសារ និងតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ៣១.០០០គ្រួសារ ចំនួនទាជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ៦២,៣ក្បាល ។

**រូបទី ៣.១៨. ចំនួនគ្រួសារកសិកម្មចិញ្ចឹមទា ចែកតាមតំបន់ ឆ្នាំ២០២១**



*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

នៅតំបន់វាលទំនាបបានបង្ហាញថាមានចំនួនទាសរុបប្រមាណ ៦,២លានក្បាល នៅតំបន់បឹងទន្លេសាប មានចំនួនប្រហែល ៦,២លានក្បាល និងនៅតំបន់ឆ្នេរសមុទ្រមានចំនួន ១,៦លានក្បាល ហើយនៅតំបន់ភ្នំ និងខ្ពង់រាប មានទាចំនួនប្រហែល ៧០០.០០០ក្បាល។

**រូបទី ៣.១៩ ចំនួនទាសរុប ចែកតាមតំបន់ ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

បម្រែបម្រួលសត្វទាក្នុងរយៈពេល១២ ខែកន្លងមក ការចិញ្ចឹមទារបស់គ្រួសារកសិកម្ម គឺបានមកពីការទិញទាចូលច្រើនជាងលើសលុបយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប មានទាកើតកូនបន្តពូជច្រើនជាងគេចំនួន ១,៥លានក្បាល បន្ទាប់មកនៅតំបន់វាលទំនាប មាន ១,១លានក្បាល ហើយតំបន់ឆ្នេរសមុទ្រ មានប្រមាណ ៥០០.០០០ក្បាល និងនៅ តំបន់ភ្នំ និងខ្ពង់រាប មាន ៣០០.០០០ក្បាល តិចជាងគេ។

**រូបទី ៣.២០. ចំនួនទាបានកើត ចែកតាមតំបន់ ឆ្នាំ២០២១**



*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

មូលហេតុចម្បង នៃការចិញ្ចឹមទាររបស់គ្រួសារកសិកម្មបានបង្ហាញថា លក់រស់មានចំនួនប្រមាណ ៥,២ លានក្បាល ហើយចំនួន ១,៣ លានក្បាល ត្រូវបានកាប់យកសាច់ និងមាន ២,៣ លានក្បាល បាន ងាប់ដោយសារធម្មជាតិ ជំងឺ និងជំងឺឆ្លងផ្សេងៗ ក្នុងរយៈពេលយោងឆ្នាំ ២០២១ ។

**រូបទី ៣.២១. ចំនួនបម្រែបម្រួលទា រយៈពេល១២ ខែកន្លងមក ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

## ការថែទាំសត្វ

ការថែទាំ បសុសត្វ បសុបក្សី របស់គ្រួសារកសិកម្មបានរាយការណ៍ថា ការព្យាបាលសត្វមានចំនួន លើសលុបច្រើនជាងការចាក់វ៉ាក់សាំងបង្ការការពារប៉ារ៉ាស៊ីតខាងក្នុង និងខាងក្រៅ។ សម្រាប់ការព្យាបាល សត្វទាំងអស់ គោមានចំនួនច្រើនជាងគេ បន្ទាប់មក មាន់ ជ្រូក ទា ក្របី។ ចំណែកការចាក់ថ្នាំបង្ការប៉ារ៉ាស៊ីត ខាងក្នុង និងខាងក្រៅ គោមានចំនួនច្រើនជាងគេ បន្ទាប់មក មាន់ ជ្រូក ក្របី ទា។

**រូបទី ៣.២២. ការថែទាំសត្វរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*